**សុន្ទរកថា**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានក្រុមប្រឹក្សាជាតិ**
**គាំពារសង្គម**

**ថ្លែងក្នុង**

**ពិធីបើក «ទិវាសប្តាហ៍គាំពារសង្គម» ប្រចាំឆ្នាំ ២០២២**

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០២២

- ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី;
- សមាជិក-សមាជិកា នៃអង្គពិធីជាទីមេត្រី !

ថ្ងៃនេះ, ខ្ញុំពិតជាមានកិត្តិយស និង ក្តីសោមនស្សជាអនេក ដោយបានចូលរួមជាអធិបតី ក្នុងកម្មវិធីបើក «**ទិវាសប្តាហ៍គាំពារសង្គមកម្ពុជា**» លើកទី ១ ប្រចាំឆ្នាំ ២០២២ ។ ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវត្តមានរបស់ ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី ដែលបានចូលរួមនៅក្នុងកម្មវិធីនាថ្ងៃនេះ, ទាំងនៅទីនេះដោយផ្ទាល់ និង តាមអនឡាញពីចម្ងាយ ។ ខ្ញុំសូមវាយតម្លៃខ្ពស់ ចំពោះ **អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម** ក្រោមការតម្រង់ទិសរបស់គណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិ ដែលបានផ្តួចផ្តើមរៀបចំកម្មវិធីដ៏មានសារៈសំខាន់នេះឡើង ។ ជាមួយគ្នានេះ, ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ចំពោះស្ថាប័នពាក់ព័ន្ធនៃអង្គការសហប្រជាជាតិ ដែលបានចូលរួមយ៉ាងសកម្មក្នុងការគិតគូររៀបចំកម្មវិធីនេះឡើង ។

«**ទិវាសប្តាហ៍គាំពារសង្គម**» ឆ្នាំនេះ ប្រព្រឹត្តទៅក្រោមប្រធានបទ «**ឆ្ពោះទៅការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមសម្រាប់គ្រប់គ្នា**» ដែលជាការសបញ្ជាក់អំពីឆន្ទៈ និង ការប្តេជ្ញាចិត្តរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម ក្នុងតួនាទីជាសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបន្ត

អភិវឌ្ឍប្រព័ន្ធគាំពារសង្គមមួយដ៏រឹងមាំ ប្រកបដោយចីរភាព និង បរិយាបន្ន ដើម្បីជាប្រយោជន៍សម្រាប់ប្រជាពលរដ្ឋគ្រប់ក្រុមគោលដៅ ។

កម្មវិធីថ្ងៃនេះ គឺជាការបោះជំហានថ្មីមួយទៀត ក្នុងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម, ទាំងការគិតគូរលើការរៀបចំគោលនយោបាយឱ្យបានគ្រប់ជ្រុងជ្រោយ, ការរួមគ្នាអនុវត្តរបប និង កម្មវិធីឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និង ការផ្តល់អត្ថប្រយោជន៍ដល់គ្រប់ក្រុមប្រជាពលរដ្ឋ ។

ដូចឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី ជ្រាបស្រាប់ហើយថា ប្រព័ន្ធគាំពារសង្គមមានលក្ខណៈស្មុគស្មាញ និង មានភាពប្រទាក់ក្រឡាច្រើន ។ ដូច្នេះ, ការគិតគូរលើគោលនយោបាយនានាពាក់ព័ន្ធប្រព័ន្ធគាំពារសង្គម ទាមទារឱ្យមានការចូលរួមមតិយោបល់ពីគ្រប់ភាគីពាក់ព័ន្ធ, ទាំងតំណាងស្ថាប័នរបស់រាជរដ្ឋាភិបាល, តំណាងនិយោជក, តំណាងនិយោជិត, ដៃគូអភិវឌ្ឍន៍ និង សង្គមស៊ីវិល, ព្រមទាំងតំណាងប្រជាពលរដ្ឋទូទៅផងដែរ, ទើបគោលនយោបាយទាំងនោះ អាចឆ្លើយតបបានសមស្រប និង គ្រប់ជ្រុងជ្រោយ ទៅនឹងតម្រូវការ និង បញ្ហាប្រឈមជាក់ស្តែងនានា ។ ក្នុងស្មារតីនេះ, ការរៀបចំ **«ទិវាសប្តាហ៍គាំពារសង្គម»** ប្រចាំឆ្នាំនេះឡើង គឺដើម្បីបង្កើតជាវេទិកាជួបជុំ រវាងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដើម្បីផ្លាស់ប្តូរមតិយោបល់រវាងគ្នានឹងគ្នាលើបញ្ហាទាំងនោះ ។

## ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី!

តាមរយៈ **គោលនយោបាយ ឈ្នះ-ឈ្នះ** និង ក្រោមការដឹកនាំដ៏ត្រឹមត្រូវ ប្រកបដោយចក្ខុវិស័យវែងឆ្ងាយ និង ភាពប្រាកដនិយម របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**, ប្រទេសកម្ពុជាបានចាកផុតពីសង្គ្រាមរ៉ាំរ៉ៃដែលបានអូសបន្លាយជាច្រើនទសវត្ស ព្រមទាំងទទួលបានយ៉ាងពេញលេញ នូវសុខសន្តិភាព, ការបង្រួបបង្រួមជាតិ, ស្ថេរភាពនយោបាយ និង សណ្តាប់ធ្នាប់សង្គម ដែលជាបុរេលក្ខខណ្ឌដ៏ចាំបាច់មិនអាចខ្វះបាន សម្រាប់ការអភិវឌ្ឍសង្គម និង សេដ្ឋកិច្ចជាតិ ។ មិនតែប៉ុណ្ណោះ, រាជរដ្ឋាភិបាលបន្តមានមហិច្ឆតាកាន់តែខ្ពស់បន្ថែមទៀត គឺការប្រែក្លាយប្រទេសកម្ពុជាពីប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ឱ្យក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និង ក្លាយជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០ ។

ដើម្បីសម្រេចបាននូវមហិច្ឆតាទាំងនេះ, ការអភិវឌ្ឍ និង ការកែទម្រង់លើគ្រប់វិស័យ គឺជាកត្តាចាំបាច់ ដែលក្នុងនោះ ការកសាងប្រព័ន្ធគាំពារសង្គមដ៏រឹងមាំមួយ គឺជាសសរស្តម្ភដ៏សំខាន់ ក្នុងការចូលរួមលើកកម្ពស់ និង អភិវឌ្ឍកត្តាមនុស្ស ដែលជាកត្តាអាទិភាពមួយ ក្នុងចំណោមកត្តាអាទិភាពទាំង ៤ សម្រាប់ការអភិវឌ្ឍជាតិ ដែលត្រូវបានកំណត់នៅក្នុង

**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៤** របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ពោលគឺៈ **មនុស្ស, ផ្លូវ, ទឹក និង ភ្លើង** ។

ទោះជាយ៉ាងនេះក្តី, វិបត្តិជំងឺកូវីដ-១៩ បានបង្កើតឧបសគ្គកាន់តែធំ សម្រាប់យើងទាំងអស់គ្នា ក្នុងការបោះជំហានឆ្ពោះទៅមុខ ។ ក៏ប៉ុន្តែ, ក្រោមការដឹកនាំ និង ការចង្អុលបង្ហាញដោយផ្ទាល់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**, កម្ពុជាសម្រេចបានសមិទ្ធផលគួរជាទីមោទនៈ ដោយអាចគ្រប់គ្រងបានយ៉ាងល្អនៃការរីករាលដាលក្នុងសហគមន៍នៃជំងឺកូវីដ-១៩ ។ ស្ថានភាពនេះបានធ្វើឱ្យកម្ពុជាមានលទ្ធភាពបើកប្រទេស និង សង្គម-សេដ្ឋកិច្ចឡើងវិញពេញលេញ និង ធ្វើឱ្យប្រជាជនកម្ពុជាអាចប្រកបមុខរបរ និង អាជីវកម្មផ្សេងៗបានជាធម្មតា ។ ជោគជ័យក្នុងការប្រយុទ្ធប្រឆាំង នឹងជំងឺកូវីដ-១៩ នេះ អាចសម្រេចទៅបាន គឺដោយមានការគិតគូរ និង មានយន្តការគ្រប់គ្រងច្បាស់លាស់ ប្រកបដោយប្រសិទ្ធភាព តាមរយៈ៖ (១)-យុទ្ធនាការចាក់វ៉ាក់សាំងដោយឥតគិតថ្លៃ គ្របដណ្តប់បានប្រមាណ ៩០% នៃប្រជាជនសរុបប្រមាណ ១៦ លាននាក់ ដែលបាន និង កំពុងបង្កើតឱ្យមានភាពស៊ាំសហគមន៍កាន់តែរឹងមាំ និង ដែលបានធ្វើឱ្យកម្ពុជាក្លាយជាប្រទេសដែលមានអត្រាចាក់វ៉ាក់សាំងកូវីដ-១៩ ខ្ពស់ ក្នុងចំណោមប្រទេសដែលមានអត្រាចាក់វ៉ាក់សាំងខ្ពស់នៅក្នុងតំបន់ និង ក្នុងពិភពលោក; (២)-ការពង្រឹងសមត្ថភាពព្យាបាល ជាមួយនឹងប្រសិទ្ធភាពនៃវ៉ាក់សាំង ក៏បានរួមចំណែកយ៉ាងសំខាន់ ដោយបានកាត់បន្ថយអត្រាស្លាប់ និង អត្រាអ្នកជំងឺធ្ងន់ដោយជំងឺកូវីដ-១៩ មកនៅត្រឹមកម្រិតទាបបំផុត; (៣)-ការដាក់ចេញនូវយុទ្ធនាការប្រើប្រាស់តេស្តរហ័សជាមួយនឹងតម្លៃសមរម្យ និង ងាយស្វែងរកទិញបាន, ការអនុញ្ញាតឱ្យព្យាបាលតាមផ្ទះ និង មន្ទីរពេទ្យឯកជន និង ការខិតខំស្វែងរកថ្នាំដែលមានប្រសិទ្ធភាពមកព្យាបាល; និង (៤)-ការដាក់ចេញនូវយុទ្ធនាការអប់រំ, ផ្សព្វផ្សាយ និង បណ្តុះបណ្តាលប្រជាពលរដ្ឋ ឱ្យយល់ដឹងអំពីគ្រោះថ្នាក់នៃមេរោគកូវីដ-១៩ ដែលនៅបន្តមានជាប់ជាប្រចាំ និង ការផ្លាស់ប្តូរឥរិយាបថ ដើម្បីរៀនរស់នៅជាបណ្តើរៗជាមួយនឹងវត្តមាននៃមេរោគកូវីដ-១៩ តាម **គន្លងប្រក្រតីភាពថ្មី** ឱ្យបានត្រឹមត្រូវ ដោយប្រកាន់ខ្ជាប់វិធានការ **៣ ការពារ និង ៣ កុំ** ។

ជាការពិតណាស់, វិបត្តិនៃជំងឺកូវីដ-១៩ បានបង្កនូវការលំបាកសម្រាប់យើងច្រើន ប៉ុន្តែការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមនៅកម្ពុជា មិនបានដើរថយក្រោយសូម្បីមួយជំហានឡើយ ។ ក្នុងអំឡុងពេលនៃវិបត្តិនេះ, របប និង កម្មវិធីគាំពារសង្គមទាំងអស់ នៅតែត្រូវបានបន្តអនុវត្តដោយមិនមានការខកខាននោះឡើយ ។ រាជរដ្ឋាភិបាលបានដាក់ចេញនូវអភិក្រមសំខាន់ៗសម្រាប់វិធានការអន្តរាគមន៍នៃប្រព័ន្ធគាំពារសង្គមចំនួន ៣ រួមមាន៖

(១)- **បន្តដំណើរការរាល់កម្មវិធីជំនួយសង្គម និង គាំពារសង្គមទាំងឡាយ ដែលមានស្រាប់ មិនឱ្យមានការខកខាននៅក្នុងអំឡុងពេលវិបត្តជំងឺកូវីដ-១៩;**

(២)- **ពិនិត្យលទ្ធភាពកែសម្រួល និង បន្ធូរបន្ថយលក្ខខណ្ឌនានា ដើម្បីជានានូវការបន្តទទួលផលរបស់ប្រជាពលរដ្ឋ** ដូចជា ការប្រែក្លាយពីការចម្អិនម្ហូបនៅតាមសាលារៀន មកជាការចែកស្បៀងអង្ករជូនគ្រួសារសិស្សក្រីក្រ និង ការពង្រីកការវិនិយោគលើកម្មវិធី **គម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និង គាំទ្រកសិករ** ជាដើម;

(៣)- **រៀបចំដាក់ឱ្យដំណើរការ នូវកម្មវិធីជំនួយសង្គមពិសេស ដើម្បីជួយសម្រួលដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋក្រីក្រ និង ងាយរងគ្រោះ** ដូចជា ការផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតនៅតាមរោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និង វិស័យទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារ និង ការផ្តល់នូវជំនួយឧបត្ថម្ភដល់គ្រួសារក្រីក្រដែលមានការលំបាកក្នុងជីវភាព នៅក្នុង និង ក្រោយរយៈពេលនៃការបិទខ្ទប់ ។ ចាប់តាំងពីខែមិថុនា ឆ្នាំ ២០២០ មក, រាជរដ្ឋាភិបាលបានអនុវត្ត **កម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់គ្រួសារក្រីក្រ និង ងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩** ដែលជាកម្មវិធីជំនួយសង្គមពិសេស និង ដែលកំពុងបន្តអនុវត្តមកដល់សព្វថ្ងៃនេះ ។ រាជរដ្ឋាភិបាលបាន និង កំពុងចំណាយថវិកាប្រមាណជាង ៣០ លានដុល្លារក្នុងមួយខែៗ សម្រាប់អនុវត្តកម្មវិធីជំនួយសង្គមពិសេសនេះ ។

បន្ថែមលើអន្តរាគមន៍ដែលមានស្រាប់, ក្រុមប្រឹក្សាជាតិគាំពារសង្គមក៏បាន និង កំពុងរៀបចំបង្កើត និង ដាក់ឱ្យដំណើរការ **ក្របខណ្ឌកិច្ចគាំពារសង្គមដើម្បីឆ្លើយតបនឹងគ្រោះអាសន្ន** (Shock Responsive Social Protection Framework) សំដៅបង្កើតជាមូលដ្ឋានរឹងមាំក្នុងការត្រៀមខ្លួនចាត់វិធានការទប់ទល់ឱ្យបានទាន់ពេល នៅពេលមានវិបត្តិកើតឡើង នាពេលអនាគតផងដែរ ។

**ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី!**

ឥទ្ធិពលនៃវិបត្តិជំងឺកូវីដ-១៩ មិនត្រឹមតែមិនបានបន្ថយបង្អាក់ការខិតខំរបស់រាជរដ្ឋាភិបាលក្នុងការជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមប៉ុណ្ណោះទេ, ប៉ុន្តែវិបត្តិនេះថែមទាំងបានជំរុញឱ្យរាជរដ្ឋាភិបាលបង្កើនការយកចិត្តទុកដាក់កាន់តែខ្លាំងឡើង លើការកសាងប្រព័ន្ធគាំពារសង្គមមួយ ឱ្យកាន់តែរឹងមាំថែមទៀត ជាពិសេស គឺការផ្តោតសំខាន់លើការកសាង **ភាពធន់**

(Resilience) ដើម្បីឆ្លើយតបនឹងវិបត្តិនានា ។ ជាក់ស្តែង, **ក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣** ដែលរាជរដ្ឋាភិបាលបានអនុម័ត និង ដាក់ឱ្យប្រើប្រាស់កាលពីខែធ្នូ ឆ្នាំ ២០២១ កន្លងទៅ បានកំណត់យ៉ាងច្បាស់ នូវគោលដៅអាទិភាពចំពោះមុខសម្រាប់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ដូចខាងក្រោម៖

១. បន្តអនុវត្ត **កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និង ងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩**;

២. កែសម្រួលកម្រិតប្រាក់ឧបត្ថម្ភនៃ **កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និង ងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩** ជាជំហានៗ ក្នុងរយៈពេលយ៉ាងហោចណាស់ ៦ ខែ មុននឹងបញ្ចប់ការឧបត្ថម្ភជាស្ថាពរ;

៣. ក្រោយពីបញ្ចប់ជាស្ថាពរនូវ **កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និង ងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩,** នឹងដាក់ឱ្យដំណើរការនូវ **កម្មវិធីជាតិជំនួយសង្គម ក្នុងក្របខណ្ឌកញ្ចប់គ្រួសារ** ដើម្បីជាទម្រក្នុងការទ្រទ្រង់ជីវភាពគ្រួសារក្រីក្រ ទៅតាមកម្រិតនៃភាពរងគ្រោះជាក់ស្តែង;

៤. ពិនិត្យលទ្ធភាពពង្រីកវិសាលភាព **កម្មវិធីផ្តល់អាហារតាមសាលារៀន ដោយប្រើប្រាស់កសិផលក្នុងសហគមន៍**;

៥. រៀបចំបង្កើតវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈសមស្រប សម្រាប់យុវជនមកពីគ្រួសារក្រីក្រ ដើម្បីបង្កើតលទ្ធភាព ឈោងចាប់យកជំនាញ និង មុខរបរ តាមរយៈការផ្តល់អាហារូបករណ៍ និង ការមិនចាំបាច់បង់ថ្លៃសាលា;

៦. សិក្សាលទ្ធផលនៃការអនុវត្តគម្រោងសាកល្បង និង ពិនិត្យលទ្ធភាពដាក់ឱ្យដំណើរការ **កម្មវិធីគាំពារសង្គមដើម្បីបញ្ចប់ភាពក្រីក្រ** តាមរយៈការផ្សាភ្ជាប់ការឧបត្ថម្ភសាច់ប្រាក់ទៅនឹងការអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ និង សហគ្រិនភាព;

៧. ដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកសោធន សម្រាប់ជនទាំងឡាយណាដែលស្ថិតក្រោមច្បាប់ការងារ;

៨. ពិនិត្យលទ្ធភាពពង្រីកវិសាលភាពជាជំហានៗនូវ **មូលនិធិសមធម៌សុខាភិបាល** និង **របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព** ដើម្បីពង្រីកការគាំពារទៅដល់ពលរដ្ឋដែលរស់នៅក្បែរបន្ទាត់នៃភាពក្រីក្រ និង ក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ;

៩. រៀបចំ **ផែនទីបង្ហាញផ្លូវ** (Roadmap) សម្រាប់ **ការគ្រប់ដណ្តប់សុខភាពជាសកល** (Universal Health Coverage) ដោយមានការគិតគូរច្បាស់លាស់ពីទិសដៅ, គោល-នយោបាយ, ការសម្របសម្រួល និង សមត្ថភាពស្ថាប័ន; និង

១០. បន្តអនុវត្ត **កម្មវិធីសាច់ប្រាក់ពលកម្ម** (Cash for Work) ដើម្បីលើកកម្ពស់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធតាមទីជនបទ និង ផ្តល់ឱកាសការងារជូនពលរដ្ឋតាមមូលដ្ឋាន ។

**ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី!**

ការរៀបចំបង្កើតឱ្យមាន «**ទិវាសប្តាហ៍គាំពារសង្គម**» នេះឡើង គឺជាផ្នែកមួយនៃការពង្រឹងគោលការណ៍អភិបាលកិច្ចល្អ នៅក្នុងប្រព័ន្ធគាំពារសង្គមកម្ពុជា អនុលោមតាមការចង្អុល-បង្ហាញរបស់ **ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥** និង **យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី ៤** របស់រាជរដ្ឋាភិបាល ។ ការបង្កើតឱ្យមានយន្តការជជែកពិភាក្សាដោយបើកចំហ រវាងគ្រប់ភាគីពាក់ព័ន្ធបែបនេះ នឹងផ្តល់ឱកាសឱ្យអ្នករៀបចំគោលនយោបាយពិសេស ក្រុមប្រឹក្សាជាតិគាំពារសង្គមផ្ទាល់ បានស្តាប់ និង ទទួលដឹងឮ អំពីលទ្ធផលនៃការ-ដាក់ចេញ នូវគោលនយោបាយនានា ដែលជាធាតុចូលយ៉ាងសំខាន់ ក្នុងការគិតគូររៀបចំនូវគោលនយោបាយនាពេលខាងមុខ ឱ្យកាន់តែប្រសើរឡើង ។ អាស្រ័យហេតុនេះ, ក្នុងនាមជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម, ខ្ញុំសូមលើកទឹកចិត្តឱ្យគ្រប់ស្ថាប័នពាក់ព័ន្ធ ចូលរួមផ្តល់មតិយោបល់ក្នុងន័យស្ថាបនា, ទាំងលើគោលនយោបាយគាំពារសង្គមជារួម និង លើការអនុវត្តរបបសន្តិសុខសង្គម ឬកម្មវិធីជាតិជំនួយសង្គមជាក់លាក់ណាមួយ, ដើម្បីឱ្យស្ថាប័នដែលទទួលបន្ទុកអនុវត្តការងារផ្ទាល់ មានលទ្ធភាពពិនិត្យ និង ពិចារណាកែតម្រូវភាពខ្វះចន្លោះនានាសំដៅធានាឱ្យប្រព័ន្ធគាំពារសង្គមកម្ពុជា ក្លាយជាប្រព័ន្ធមួយដែលមានប្រសិទ្ធភាព, ចីរភាព, សមធម៌ និង បរិយាបន្ន ។

ក្រៅពីការរៀបចំឱ្យមានវេទិកាពិភាក្សានេះឡើង, រាជរដ្ឋាភិបាលក៏បានរៀបចំបង្កើតយន្តការការងារផ្សេងៗទៀត ក្នុងគោលដៅជំរុញ និង លើកកម្ពស់គោលការណ៍អភិបាលកិច្ចល្អក្នុងប្រព័ន្ធគាំពារសង្គម ឱ្យកាន់តែមានភាពប្រសើរឡើងជាលំដាប់ ដើម្បីធានាថា ការអនុវត្តគោលនយោបាយគាំពារសង្គម ប្រព្រឹត្តទៅប្រកបដោយតម្លាភាព និង គណនេយ្យភាពត្រឹមត្រូវក្នុងនោះ រួមមាន៖

១. ការដាក់ឱ្យដំណើរការនូវ **យន្តការតាមដាន និង វាយតម្លៃ** (Monitoring and Evaluation) ក្នុងប្រព័ន្ធគាំពារសង្គម ដែលប្រព័ន្ធនេះនឹងតម្រូវឱ្យស្ថាប័នពាក់ព័ន្ធទាំងអស់

រាយការណ៍មកក្រុមប្រឹក្សាជាតិ អំពីវឌ្ឍនភាពនៃការអនុវត្តការងារជាប្រចាំ និង មានលក្ខណៈជាប្រព័ន្ធ (Systematic) ច្បាស់លាស់ និង

២.ការដាក់ឱ្យដំណើរការនូវ **និយ័តករសន្តិសុខសង្គម** នៅក្រោមឆ័ត្ររបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដើម្បីត្រួតពិនិត្យជាប្រចាំ នូវភាពរឹងមាំផ្នែកហិរញ្ញវត្ថុ និងការបំពេញការងាររបស់ប្រតិបត្តិករសន្តិសុខសង្គម ។

មុននឹងបញ្ចប់, ជាថ្មីម្តងទៀត, ខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី ដែលបានចំណាយពេលដ៏មានតម្លៃ ចូលរួមក្នុងកម្មវិធីនាថ្ងៃនេះ ។ ខ្ញុំក៏សូមជូនពរឱ្យទិវាមួយនេះ ដំណើរការប្រកបដោយផ្លែផ្កា ដែលនឹងផ្តល់ជាមូលដ្ឋានក្នុងការរៀបចំវេទិកានៅឆ្នាំក្រោយៗទៀត ។

ជាទីបញ្ចប់, ខ្ញុំសូមប្រសិទ្ធពរជ័យជូនឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រីទាំងអស់ ជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ និង ពលៈ** និងសូមជៀសឆ្ងាយពីជំងឺកូវីដ-១៩ ។

ខ្ញុំសូមប្រកាសបើកដំណើរការជាផ្លូវការនូវ **«ទិវាសប្តាហ៍គាំពារសង្គម»** ចាប់ពីពេលនេះតទៅ ។

**សូមអរគុណ!**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម
លេខ: ...... /អ.ក.គ.........

# សន្ទរកថាស្វាគមន៍
# របស់ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
# និងជាប្រធានគណៈកម្មាធិការប្រតិបត្តិក្រុមប្រឹក្សាជាតិគាំពារសង្គម
# ថ្លែងក្នុង
# ពិធីបើកទិវាសប្តាហ៍គាំពារសង្គម ប្រចាំឆ្នាំ២០២២
# រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០២២

- **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម ជាទីគោរពដ៏ខ្ពង់ខ្ពស់**
- **ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាក្រុមប្រឹក្សាជាតិគាំពារសង្គម ថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន និងថ្នាក់ដឹកនាំដៃគូអភិវឌ្ឍន៍**
- **ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ!**

ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ក្នុងការស្វាគមន៍ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី ក្នុងកម្មវិធី "**វេទិកាសប្តាហ៍គាំពារសង្គម**" នាពេលនេះ។ ជាបឋម ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម** ដែលបានចំណាយពេលវេលាដ៏មមាញឹក អញ្ជើញជាអធិបតីក្នុងកម្មវិធីបើក "**ទិវាសប្តាហ៍គាំពារសង្គម**" ប្រចាំឆ្នាំ២០២២ នាព្រឹកនេះ។ ខ្ញុំក៏សូមសម្តែងនូវការស្វាគមន៍ផងដែរចំពោះវត្តមានរបស់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី តំណាងក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល និយោជក និយោជិត ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិលនានា។

កម្មវិធីថ្ងៃនេះ គឺជាការបោះជំហានថ្មីមួយទៀតនៃប្រព័ន្ធគាំពារសង្គមកម្ពុជា ក្នុងការឆ្ពោះទៅការកសាងប្រព័ន្ធគាំពារសង្គមមួយប្រកបដោយចីរភាព ដើម្បីធានាបាននូវសន្តិសុខប្រាក់ចំណូលសម្រាប់គ្រប់គ្នា

តាមរយៈការគិតគូររៀបចំគោលនយោបាយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដែលមានការចូលរួមមតិយោបល់ពីគ្រប់ភាគីពាក់ព័ន្ធ។

កម្មវិធី "**ទិវាសប្តាហ៍គាំពារសង្គម**" ដែលបើកឱ្យដំណើរការនាពេលនេះ គឺជាវេទិកាថ្នាក់ជាតិលើកទី១ ដែលរៀបចំឡើងរយៈពេល ៣ ថ្ងៃ គឺ÷

**ថ្ងៃទី១÷** ជាវេទិកាពិភាក្សាកម្រិតគោលនយោបាយ ដើម្បីផ្តល់ឱកាសឱ្យស្ថាប័នពាក់ព័ន្ធធ្វើការពិភាក្សា និងផ្លាស់ប្តូរមតិយោបល់លើការរៀបចំគោលនយោបាយគាំពារសង្គម។ គ្រប់ភាគីពាក់ព័ន្ធត្រូវបានអញ្ជើញចូលរួមក្នុងកិច្ចពិភាក្សា ដែលរួមមាន÷ តំណាងដែលជាថ្នាក់ដឹកនាំមកពីក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល តំណាងនិយោជក តំណាងនិយោជិត ដៃគូអភិវឌ្ឍន៍ និង សង្គមស៊ីវិល។

**ថ្ងៃទី២÷** ជាវេទិកាពិភាក្សាកម្រិតបច្ចេកទេស ដើម្បីផ្តល់ឱកាសឱ្យស្ថាប័នពាក់ព័ន្ធ ទាំងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ចូលរួមផ្តល់មតិយោបល់លើការអនុវត្ត និងបញ្ហាប្រឈមនានាក្នុងការអត្ថប្រយោជន៍គាំពារសង្គមនានាដល់ក្រុមប្រជាជនគោលដៅ។

**ថ្ងៃទី៣÷** ជាវេទិកាលើកកម្ពស់ចំណេះដឹងសម្រាប់សាធារណជន អំពីអត្ថប្រយោជន៍នៃប្រព័ន្ធគាំពារសង្គម ក្នុងការលើកកម្ពស់សុខុមាលភាពរបស់ពួកគាត់ និងក្រុមគ្រួសារ។

កម្មវិធី "**វេទិកាសប្តាហ៍គាំពារសង្គម**" លើកទី១ ដែលប្រារព្ធឡើងក្នុងឆ្នាំនេះ ផ្តោតលើប្រធានបទ "**ឆ្ពោះទៅការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមសម្រាប់គ្រប់គ្នា**" ដោយមានការចូលរួមពីភាគីពាក់ព័ន្ធមានចំនួនសរុបប្រមាណជាង ៥០០ នាក់ ទាំងការចូលរួមដោយផ្ទាល់ និងតាមរយៈប្រព័ន្ធវីដេអូប្រជុំពីចម្ងាយ (Zoom) ព្រមទាំងមានការផ្សាយផ្ទាល់លើបណ្តាញសង្គមផ្សេងៗផងដែរ ដើម្បីឆ្លើយតបទៅនឹងការរស់នៅតាមបែបគន្លងថ្មី ក្នុងបរិបទដែលជំងឺកូវីដ-១៩ នៅតែបន្តជាការគម្រាមកំហែង។

***ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី***

ប្រព័ន្ធគាំពារសង្គមកម្ពុជាបាន និងកំពុងបោះជំហានទៅមុខប្រកបដោយវឌ្ឍនភាព ក្រោមការចង្អុលបង្ហាញរបស់ "**ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥**" និងក្រោមការដឹកនាំ និងតម្រង់ទិសរបស់ "**ក្រុមប្រឹក្សាជាតិគាំពារសង្គម**" ដែលមាន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ជាប្រធាន។ ចាប់តាំងពីការបង្កើតឡើងនៅខែមិថុនា ឆ្នាំ២០១៧ មក, ក្រុមប្រឹក្សាជាតិគាំពារសង្គម បានអនុម័ត និងដាក់ឱ្យដំណើរការនូវរបប និងកម្មវិធីជាតិគាំពារសង្គមសំខាន់ៗជាច្រើន។ ជាពិសេស អ្វីដែលយើងគ្រប់គ្នាគួរមានមោទនភាពបំផុតនោះគឺការដាក់ឱ្យអនុវត្ត "**កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩**" ដែលបានជួយសម្រួលដល់ជីវភាពប្រជាពលរដ្ឋជាង ២ លាននាក់ ហើយដែលបាន និងកំពុងបន្តអនុវត្តរហូតមកដល់ពេលនេះ។

ក្នុងនាមខ្ញុំជាប្រធានគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម ខ្ញុំពិតជាមានមោទនភាពយ៉ាងក្រៃលែង ដែលបានចូលរួមចំណែកជ្រុមជ្រែង គាំទ្រ និងអនុវត្ត តាមការចង្អុលបង្ហាញរបស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** លើការដាក់ចេញនូវគោលនយោបាយនានា ដែលបានបង្ហាញចេញនូវផ្លែផ្កាជាទីមោទនៈសម្រាប់ជាប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប។

***ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី***

ការរៀបចំកម្មវិធី **"វេទិកាសប្តាហ៍គាំពារសង្គម"** នេះឡើង គឺបង្ហាញឱ្យឃើញច្បាស់អំពីឆន្ទៈរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម ក្នុងការបន្តអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឱ្យកាន់តែរលូន និងមានប្រសិទ្ធភាពខ្ពស់ តាមរយៈការផ្តល់ឱកាសឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ទាំងស្ថាប័នរបស់រាជរដ្ឋាភិបាល តំណាងនិយោជក តំណាងនិយោជិត ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល ចូលរួមផ្តល់មតិយោបល់ ឱ្យកាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងបម្រើដល់ផលប្រយោជន៍សង្គមជាតិទាំងមូល។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះស្ថាប័នពាក់ព័ន្ធនៃអង្គការសហប្រជាជាតិ ជាពិសេសអង្គការអន្តរជាតិខាងការងារ (ILO) ដែលបានផ្តល់កិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ក្នុងការរៀបចំកម្មវិធីដ៏មានសារៈសំខាន់នេះឡើង។

ជាចុងក្រោយនេះ ខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម** ដែលអញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងកម្មវិធីបើក **ទិវាសប្តាហ៍គាំពារសង្គម** និងការចូលរួមកិច្ចសហការ និងការគាំទ្រពីភាគីពាក់ព័ន្ធ ព្រមទាំង **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ដែលអញ្ជើញមកពីបណ្តាក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងមន្ទីរ តាមបណ្តារាជធានីខេត្តទាំងអស់នៅទូទាំងប្រទេស ដែលបានចំណាយពេលវេលាចូលរួមកម្មវិធីនៅថ្ងៃនេះ ទាំងនៅទីនេះផ្ទាល់ និងតាមប្រព័ន្ធប្រជុំពីចម្ងាយ។

ខ្ញុំសូមគោរពជូនពរ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ** សូមប្រកបដោយសុខភាពល្អ, កម្លាំងមាំមួន សម្រេចបានជោគជ័យក្នុងគ្រប់ភារកិច្ច ទទួលបាននូវសុភមង្គលក្នុងក្រុមគ្រួសាររៀងៗខ្លួន និងសូមបន្តរួមគ្នាកសាងប្រព័ន្ធគាំពារសង្គមមួយដែលរឹងមាំសម្រាប់ព្រះរាជាណាចក្រកម្ពុជា។

សូមអរគុណ!

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម

គាំពារសង្គមកម្ពុជា
SOCIAL PROTECTION IN CAMBODIA

ថ្ងៃអង្គារ ១៤កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែ កុម្ភៈ ឆ្នាំ ២០២២

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ទិវាសប្តាហ៍គាំពារសង្គម

នៅព្រឹកថ្ងៃអង្គារ ១៤កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី១៥ ខែ កុម្ភៈ ឆ្នាំ ២០២២, **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម បានអញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់បើក“**ទិវាសប្តាហ៍គាំពារសង្គម**” (Social Protection Week) ដោយមានការចូលរួមពីថ្នាក់ដឹកនាំនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការជាតិ-អន្តរជាតិ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធ ទាំងចូលរួមផ្ទាល់ និងចូលរួមតាមប្រព័ន្ធប្រជុំពីចម្ងាយ សរុបចំនួនប្រមាណ ៦០០នាក់។“**ទិវាសប្តាហ៍គាំពារសង្គម**” នេះ នឹងប្រព្រឹត្តទៅរយៈពេល ៣ថ្ងៃ គឺពីថ្ងៃទី១៥ ដល់ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២។

“**ទិវាសប្តាហ៍គាំពារសង្គម**” ជាទិវាមួយដែលបានប្រារព្ធធ្វើឡើងក្នុងប្រទេសជាច្រើនក្នុងសកលលោក ដើម្បីពង្រឹងការយល់ដឹង និងសារៈសំខាន់នៃកម្មវិធី និងគោលនយោបាយគាំពារសង្គមរបស់ប្រទេសនីមួយៗ ក្នុងការរួមចំណែកលើកកម្ពស់សុខុមាភាពរបស់ប្រជាពលរដ្ឋទូទៅ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវកម្រិតជីវភាពរបស់ប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះ ព្រមទាំងជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន សមធម៌ និងចីរភាព។

សម្រាប់ប្រទេសកម្ពុជា, “**ទិវាសប្តាហ៍គាំពារសង្គម**” ត្រូវបានប្រារព្ធធ្វើឡើងជាលើកដំបូង ជាមួយនឹងប្រធានបទ “**ឆ្ពោះទៅការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមសម្រាប់គ្រប់គ្នា** ” ដែលសហការរៀបចំឡើងដោយក្រុមប្រឹក្សាជាតិគាំពារសង្គម និងអង្គការសហប្រជាជាតិប្រចាំព្រះរាជាណាចក្រកម្ពុជា។ ដូចប្រទេសដទៃដែរ ការរៀបចំទិវាសប្តាហ៍គាំពារសង្គមរបស់ព្រះរាជាណាចក្រកម្ពុជានាពេលនេះ ធ្វើឡើងក្នុងគោលបំណងលើកកម្ពស់ការយល់ដឹង និងសារៈសំខាន់នៃប្រព័ន្ធគាំពារសង្គមនៅកម្ពុជា ការផ្សព្វផ្សាយនូវសមិទ្ធផលថ្មីៗដែលសម្រេចបាន ព្រមទាំងផ្តល់ឱកាស និងវេទិកា

ដល់តួអង្គពាក់ព័ន្ធ ពិគ្រោះពិភាក្សាលើការងារជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមនៅកម្ពុជា ទៅមួយកម្រិតទៀត ទាំងក្នុងទិដ្ឋភាពកម្រិតគោលនយោបាយ និងកម្រិតបច្ចេកទេស។

ក្នុងឱកាសនេះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានរំលឹកថា “**តាមរយៈគោលនយោបាយឈ្នះ-ឈ្នះ និងក្រោមការដឹកនាំដ៏ត្រឹមត្រូវប្រកបដោយចក្ខុវិស័យវែងឆ្ងាយ និងភាពប្រាកដនិយមរបស់ សម្តេចតេជោនាយករដ្ឋមន្ត្រី ទើបប្រទេសកម្ពុជាទទួលបាននូវសុខសន្តិភាព, ការបង្រួបបង្រួមជាតិ, ស្ថេរភាពនយោបាយ, និងសណ្តាប់ធ្នាប់សង្គម ដែលជាបុរេលក្ខខណ្ឌចាំបាច់មិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចជាតិ**”។ មិនតែប៉ុណ្ណោះ ក្រោមការដឹកនាំដោយផ្ទាល់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** កម្ពុជាក៏សម្រេចបានលទ្ធផលគួរជាទីមោទនៈ ដោយអាចគ្រប់គ្រងបានយ៉ាងល្អនៃការរីករាលដាលក្នុងសហគមន៍នៃជំងឺកូវីដ-១៩ តាមរយៈការដាក់ចេញយន្តការគ្រប់គ្រងច្បាស់លាស់ប្រកបដោយប្រសិទ្ធភាព។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានបន្តថា “**ឥទ្ធិពលនៃវិបត្តិជំងឺកូវីដ-១៩ មិនត្រឹមតែមិនបានបន្ទុចបង្អាក់ការខិតខំរបស់រាជរដ្ឋាភិបាលក្នុងការជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមប៉ុណ្ណោះទេ ប៉ុន្តែវិបត្តិនេះថែមទាំងបានជំរុញឱ្យរាជរដ្ឋាភិបាលបង្កើនការយកចិត្តទុកដាក់កាន់តែខ្លាំងឡើង ក្នុងការកសាងប្រព័ន្ធគាំពារសង្គមមួយឱ្យកាន់តែរឹងមាំថែមទៀត ជាពិសេស គឺការផ្តោតសំខាន់លើការកសាងភាពធន់ដើម្បីឆ្លើយតបនឹងវិបត្តិនានា**”។

ជាក់ស្តែង គោលដៅអាទិភាពសម្រាប់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា បានកំណត់យ៉ាងច្បាស់នៅក្នុង “**ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣**” ដែលរាជរដ្ឋាភិបាលបានអនុម័ត និងដាក់ឱ្យប្រើប្រាស់កាលពីខែធ្នូ ឆ្នាំ២០២១កន្លងទៅ។

ការរៀបចំបង្កើតឱ្យមាន “**ទិវាសប្តាហ៍គាំពារសង្គម**” នេះឡើង គឺជាផ្នែកមួយនៃការពង្រឹងគោលការណ៍អភិបាលកិច្ចល្អនៅក្នុងប្រព័ន្ធគាំពារសង្គមកម្ពុជា អនុលោមតាមការចង្អុលបង្ហាញរបស់ “**ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥**” និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ នាពេលកន្លងទៅ របស់រាជរដ្ឋាភិបាល។ ការបង្កើតឱ្យមានយន្តការជជែកពិភាក្សាដោយបើកចំហរ រវាងគ្រប់ភាគីពាក់ព័ន្ធបែបនេះ នឹងផ្តល់ឱកាសឱ្យអ្នករៀបចំគោលនយោបាយបានស្តាប់ និងដឹងអំពីលទ្ធផលនៃការដាក់ចេញនូវគោលនយោបាយនានា ដែលជាធាតុចូលយ៉ាងសំខាន់ក្នុងការគិតគូរដាក់ចេញនូវគោលនយោបាយគាំពារសង្គមនៅពេលខាងមុខឱ្យកាន់តែប្រសើរឡើង។

ក្រៅពីការរៀបចំឱ្យមានវេទិកាពិភាក្សានេះឡើង រាជរដ្ឋាភិបាលក៏បានរៀបចំបង្កើតយន្តការការងារផ្សេងៗទៀត ក្នុងគោលដៅជំរុញ និងលើកកម្ពស់ គោលការណ៍អភិបាលកិច្ចល្អក្នុងប្រព័ន្ធគាំពារសង្គមឱ្យកាន់តែមានភាពប្រសើរឡើងជាលំដាប់ ដើម្បីធានាថាការអនុវត្តគោលនយោបាយគាំពារសង្គមប្រព្រឹត្តទៅប្រកបដោយតម្លាភាព និងគណនេយ្យភាព។

ក្រោមកិច្ចសហការល្អរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការជាតិ-អន្តរជាតិ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធ, កម្ពុជារំពឹងថានឹងជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមរបស់ខ្លួនឱ្យកាន់តែប្រសើរឡើងថែមទៀត ដែលនឹងរួមចំណែកយ៉ាងសំខាន់ក្នុងការកសាងសង្គមមួយប្រកបដោយសុខដុមរមនីយកម្ម និងជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព បរិយាបន្ន និងសមធម៌ ស្របតាមគោលនយោបាយកាត់បន្ថយភាពក្រីក្រ របស់រាជរដ្ឋាភិបាល។